# ដំណឹងជ្រើសរើសសហគ្រិនកសិកម្មវ័យក្មេង

## សាវតា

អង្គការភាពជាដៃគូដើម្បីចីរភាពវិស័យកសិកម្មកម្ពុជា (CPSA) គឺជាអង្គការដៃគូប្រចាំប្រទេសរបស់ Grow Asia ក្នុងប្រទេសកម្ពុជា ដែលធ្វើការយ៉ាងជិតស្និតជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងភ្នាក់ងាររដ្ឋាភិបាលផ្សេងៗទៀត ក៏ដូចជាផ្នែកឯកជន និងអង្គការកសិករ។ CPSA ធ្វើការរួមគ្នាជាមួយក្រុមហ៊ុន ភ្នាក់ងាររដ្ឋាភិបាល អង្គការសង្គមស៊ីវិល ក្រុមកសិករ និងស្ថាប័នហិរញ្ញវត្ថុ ដើម្បីភ្ជាប់កសិករខ្នាតតូច ទៅកាន់ទីផ្សារ។ គោលបំណងរួមគឺដើម្បីបង្កើនប្រាក់ចំណូល និងផលិតភាពរបស់កសិករ ព្រមទាំងជម្រុញឱ្យមាននិរន្តរភាពបរិស្ថានសម្រាប់ការងារកសិកម្ម។ បន្ថែមពីនេះផងដែរ CPSA ក៏កំពុងធ្វើការគាំទ្រក្រុមការងារចំនួន៤មានដូចជា៖ ស្វាយចន្ទី ម្រេច ផ្លែឈើ និងបន្លែ និងសហគ្រាសធុនតូច និងមធ្យមផ្នែក កសិ-អាហារ និងបញ្ហាដទៃសំខាន់ចំនួន៣ទៀត (កសិកម្មតាមកិច្ចសន្យា ការវិនិយោគកសិកម្មប្រកបដោយភាពទទួលខុសត្រូវ និងបច្ចេកវិទ្យាកសិកម្ម)។

សហគ្រិនខ្មែរ (KE) ដែលជាស្ថាប័នមួយស្ថិតនៅក្រោម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានចក្ខុវិស័យក្លាយជាវេទិការថ្នាក់ជាតិ សម្រាប់ការលើកកម្ពស់គ្រប់សកម្មភាពរបស់វិស័យសហគ្រិនក្នុងប្រទេសកម្ពុជា។ បេសកម្មរបស់ សហគ្រិនខ្មែរ គឺ ផ្តល់ការគាំទ្រសហថាមពល និងកសាងប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព ឱ្យមានភាពរស់រវើក ដែលគាំទ្រដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ចនិងនវានុវត្តន៍ ការបង្កើនផលិតភាព និងការបង្កើតការងារ។ ដើម្បីសម្រេចបេសកម្មរបស់ខ្លួន សហគ្រិនខ្មែរ ផ្តោតលើកម្មវិធីស្នូលចំនួន៤រួមមាន ការលើកកម្ពស់វប្បធម៌សហគ្រិនភាព, ការអភិវឌ្ឍសមត្ថភាព, បណ្តាញទំនាក់ទំនង និងការផ្តល់មូលនិធិដើមទុន។

ក្នុងដើមឆ្នាំ២០២១ CPSA បានទទួលការគាំទ្រពី សហគ្រិនខ្មែរ តាមរយៈកិច្ចសហការជាដៃគូ ដើម្បីអនុវត្តកម្មវិធីបណ្តុះធុរកិច្ចថ្មី "សហគ្រិនក្នុងសហគមន៍កសិកម្ម "។ កម្មវិធី នេះមានរយៈពេល៣ឆ្នាំ ក្នុងគោលបំណង បង្កើត ឧស្សាហកម្មកសិកម្មប្រកបដោយផលិតភាពខ្ពស់ និងមាននិរន្តរភាព ដោយធ្វើការជាមួយក្រុមគោលដៅចំនួន២រួមមានយុវជន និងក្រុមកសិករ។ គម្រោងនេះមានសមាសភាពសំខាន់ៗចំនួន២គឺ ទី១ "ការបណ្តុះ ធុរកិច្ចថ្មី" ដែលយុវជន ត្រូវបានផ្តល់ការបណ្តុះបណ្តាលពីបច្ចេកទេសកសិកម្ម សហគ្រិនភាព និងជំនាញ ធុរកិច្ច ក្នុងរយៈពេល៤ខែ និង ទី២ "ការចុះកម្មសិក្សា" របស់យុវជន រយៈពេលមួយឆ្នាំ នៅតាមសហគមន៍កសិកម្ម ក្នុងខេត្តគោលដៅដូចជា កំពង់ចាម និងកំពង់ធំ ដើម្បីគាំទ្រកសិករ និងសហគមន៍ជនបទ។

គម្រោងកំពុងធ្វើការជ្រើសរើសសហគ្រិនកសិកម្មវ័យក្មេង ដើម្បីទទួលបានឱកាសបណ្តុះបណ្តាលក្នុងវគ្គបណ្តុះធុរកិច្ចថ្មី និង ការចុះកម្មសិក្សាជាមួយសហគមន៍កសិកម្ម ដែលមានលក្ខខណ្ឌមួយចំនួនដូចខាងក្រោម៖

## យុវជនដែលគម្រោងកំពុងស្វែងរក

- យុវជនដែលបានរៀនចប់យ៉ាងហោចណាស់ថ្នាក់ទី៩
- មានការតាំងចិត្តខ្ពស់ធ្វើការងារក្នុងវិស័យកសិកម្ម ធុរកិច្ចកសិកម្ម និងការកែច្នៃចំណីអាហារ
- មានឆន្ទៈធ្វើការងារជាក្រុម និងជាមួយសហគមន៍ជនបទ
- ចង់ក្លាយជាសហគ្រិនកសិកម្ម
- មានគំនិតប្រកបដោយនវានុវត្តន៍ ក្នុងការបង្កើត គំរូធុរកិច្ចថ្មីៗក្នុងវិស័យកសិកម្ម
- មានចិត្តទូលាយ និងការប្តេជ្ញាខ្ពស់ក្នុងការរៀនសូត្រ និងចែករំលែកជាមួយសហគមន៍

## លក្ខខណ្ឌក្នុងការជ្រើសរើស

- យុវជនដែលបានរៀនចប់យ៉ាងហោចណាស់ថ្នាក់ទី៩
- ធ្លាប់ធ្វើការងារ ឬស្ម័គ្រចិត្តជាមួយសហគមន៍ជនបទត្រូវបានផ្តល់អាទិភាព
- មានផ្នត់គំនិតសហគ្រិន ឬក៏ចំណាប់អារម្មណ៍ក្នុងការចូលរួមបង្កើតឲ្យមានបរិយាកាសសហគ្រិនភាព
- មានឆន្ទៈក្នុងការស្នាក់នៅភ្នំពេញអំឡុងពេលបណ្តុះបណ្តាលរយៈពេល៤ខែ
- មានឆន្ទៈក្នុងការស្នាក់នៅ និងធ្វើការជាមួយសហគមន៍កសិកម្ម បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាល
- យុវជនដែលកំពុងរស់នៅក្នុងតំបន់ ឬខេត្តគោលដៅដូចជា កំពង់ចាម និងកំពង់ធំ ត្រូវបានលើកទឹកចិត្តខ្ពស់ក្នុងការដាក់ពាក្យសុំ
- ស្ត្រីត្រូវបានលើកទឹកចិត្តខ្ពស់ក្នុងការដាក់ពាក្យសុំ

## អត្ថប្រយោជន៍ និងឱកាសទទួលបាន

- ចំណេះដឹង ជំនាញ និងបទពិសោធ ពីការអនុវត្តផ្ទាល់ ទាក់ទងនឹងបច្ចេកទេសកសិកម្ម សហគ្រិនភាព និងជំនាញការគ្រប់គ្រង ធុរកិច្ច
- ឱកាសរៀនសូត្រពីអ្នកជំនាញ និងអនុវត្តការងារជាក់ស្តែងក្នុងសហគមន៍កសិកម្ម
- ការគាំទ្រពីគម្រោងក្នុងពេលវគ្គបណ្តុះបណ្តាល និង អំឡុងពេលចុះកម្មសិក្សាជាមួយសហគមន៍កសិកម្ម
- បន្តទទួលបានឱកាសប្រឹក្សាយោបល់ និងការណែនាំពីអ្នកជំនាញក្នុងអំឡុងពេលចុះកម្មសិក្សាក្នុងការកសាងទំនាក់ទំនងជាមួយវិស័យឯកជន សង្គមស៊ីវិល និងរដ្ឋាភិបាល តាមរយៈការអភិវឌ្ឍ ធុរកិច្ច និងការស្វែងរកទីផ្សារ សម្រាប់សហគមន៍កសិកម្ម
- អាចក្លាយជាសហគ្រិនក្នុងវិស័យកសិកម្មនាពេលអនាគត

## ពាក្យស្នើសុំ និងសំណួរផ្សេងៗ

- បេក្ខជនអាចទំនាក់ទំនងសហគមន៍កសិកម្ម អង្គាធរមូលដ្ឋានដើម្បីទទួលយកពាក្យសុំបំពេញ
- ឬទាក់ទងទូរស័ព្ទ៖ ០៩៦ ២៤៨០ ៧៩៥ (សុខ សុធារតន៍) និង ០១២ ៥៥៤ ៥១១
- **កាលបរិច្ឆេទផុតកំណត់: ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០២១ ម៉ោង៥:00ល្ងាច**